ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម ។
កណ្ដាល. ថ្ងៃទី09 ខែ 6 ឆ្នាំ២០14
ក្រឡាបញ្ជី
[redacted]

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៩១០អក
ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១២
សាលក្រមលេខ៖ ០៥ (ឆ.វ.ន)
ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជំនុំជំម្រះជាសាធារណៈនៅសាលាដំបូងខេត្តកណ្ដាលនាថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០១៣ វេលាម៉ោង ១០ ព្រឹកដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជំម្រះសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងរបស់សាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៩១០អក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១២ ដែលមានជនជាប់ចោទ៖

១/ឈ្មោះ: [redacted] ភេទប្រុស អាយុ ៤៨ឆ្នាំ ជាតិខ្មែរ អាចទីកន្លែងកំណើត នៅភូមិចំការជោ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល និងមានទីលំនៅបច្ចុប្បន្នភូមិក្ដីចាស់ ឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] (ស្លាប់) ម្ដាយឈ្មោះ [redacted]) មានប្រពន្ធឈ្មោះ: [redacted](រ) មានកូន ០៤ នាក់។

ត្រូវដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យពីបទ៖ ធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ដោយសារការប្រើប្រាស់វិធីគ្រោះថ្នាក់ដល់បុគ្គល ប្រព្រឹត្តនៅភូមិក្ដីចាស់ ឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៤១៣ នៃក្រមព្រហ្មទណ្ឌ ។

**ដំណើររឿងហេតុមានដូចតទៅ**

នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង៩ ព្រឹក មានឈ្មោះ: [redacted] និងប្រពន្ធឈ្មោះ: [redacted] បានព្រមព្រៀងលែងលះគ្នានៅសាលាឃុំព្រែកលួង ដោយឈ្មោះ: [redacted] បានទៅរស់នៅស្រុកកំណើតរបស់ខ្លួននៅស្រុកអង្គស្នួល ហើយលុះដល់ថ្ងៃកើតហេតុនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០១២ វេលាម៉ោង ២១ យប់ មានឈ្មោះ: [redacted] បានជិះម៉ូតូត្រឡប់មកផ្ទះប្រពន្ធឈ្មោះ: [redacted] ស្ថិតនៅភូមិក្ដីចាស់ ឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ដោយរកប្រពន្ធមិនឃើញ ស្រាប់

Scanned by CamScanner

តែជនជាប់ចោទបានយកដែកកេះដុតខ្មៅយដេក បណ្តាលឲ្យឆេះនោបផ្ទះ ប៉ុន្តែត្រូវបានអ្នកជិតខាងជួយពន្លត់ទាន់ពេល ហើយមួយសន្ទុះសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនឈ្មោះ[redacted]តែម្តង។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ០៦០ ដកសព ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

បានឃើញ ដីកាដំណោះស្រាយលេខៈ ០៨៨ ដកដស ចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ២០១៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល។

បានឃើញ ចំណារចាត់តាំងចៅក្រមជំនុំជម្រះ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣ ។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ [redacted]បានឆ្លើយសារភាពថា កាលពីទី២៧ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោងប្រហែល ២០ យប់ ខ្លួនបានជិះម៉ូតូមកផ្ទះរបស់ប្រពន្ធខ្លួន ប៉ុន្តែពេលមកដល់មិនឃើញប្រពន្ធកូននៅផ្ទះ ហើយផ្ទះបានចាក់សោរជិត ខ្លួនក៏ឡើងយកខ្នើយមកដេកលេងនៅលើរានហាលតែម្នាក់ឯង ហើយដល់ម៉ោង ២១ ខ្លួននៅតែមិនឃើញប្រពន្ធមក ក៏បានយកដែកកេសពីហោប៉ៅយកទៅដុតខ្នើយដាក់លើនោបផ្ទះ ធ្វើអំពីឫស្សីបន្ទាប់មកខ្លួនក៏ជិះម៉ូតូចេញពីផ្ទះទៅផ្សារព្រែកលួង ហើយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតាមផ្លូវតែម្តង។ ខ្លួនដឹងថាដុតខ្នើយដាក់លើនោបផ្ទះ នឹងអាចបណ្តាលឱ្យឆេះផ្ទះ។ ខ្លួន និងប្រពន្ធខ្លួនបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ។ កន្លងមកខ្លួនពិតជាធ្លាប់វាយធ្វើបាបប្រពន្ធមែន។ ខ្លួនស្នើសុំដល់តុលាការជួយបន្ធូរបន្ថយទោសផង ព្រោះខ្លួនដឹងកំហុសហើយ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]បានឆ្លើយថាៈ កាលពីថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ២០១២ ពេលខ្លួនកំពុងធ្វើការនៅកោះពេជ្រ រាជធានីភ្នំពេញ ស្រាប់តែកូនស្រីឈ្មោះ[redacted]បានរត់មកប្រាប់ខ្លួនថា "ម៉ែអើយ ពុកដុតផ្ទះ ម៉ែឯងទៅមើលមួយភ្លែត" ពេលឮដូចនេះខ្លួនបានជិះម៉ូតូជាមួយកូនទៅមើលផ្ទះ ក៏បានឃើញនោបឫស្សីផ្ទះរបស់ខ្លួនឆេះខូចខាតចំនួនពីរកន្លែង គឺដោយសារប្តីរបស់ខ្លួនដុតបំផ្លាញ កាលពីយប់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១២។ ខ្លួនបានលែងលះជាមួយឈ្មោះ[redacted] នៅសាលាឃុំរួចហើយ ព្រោះឈ្មោះ[redacted]ឧស្សាហ៍ប្រើហិង្សាមកលើខ្លួន។ ពេលរៀបការខ្លួនមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ។ ខ្លួនមិនធ្វើការទាមទារសំណងអ្វីទេ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយថាៈ កន្លងមកឪពុកចុងខ្លួនឈ្មោះ[redacted]បានវាយបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនៅក្នុងផ្ទះ និងប្រើអំពើហិង្សាលើម្តាយខ្លួនឈ្មោះ[redacted] មិនហ៊ានស្នាក់នៅលើផ្ទះនេះទេ គឺចាក់សោរទ្វារផ្ទះរហូតទៅធ្វើជាកម្មកររស់ណាង់នៅរាជធានីភ្នំពេញ។ រហូតដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង ២២ និង០០នាទី ពេលខ្លួនកំពុងនៅផ្ទះយាយឈ្មោះ [redacted]នៅភូមិឃុំជាមួយខ្លួនដែរ ស្រាប់តែឃើញឈ្មោះ[redacted]ភេទប្រុស មកប្រាប់ខ្លួនថា ឪពុកចុងខ្លួនឈ្មោះ[redacted]បានដុតផ្ទះចោលហើយ លឺដូច្នេះខ្លួនក៏ដើរទៅមើល ពេលទៅដល់ខ្លួនបានឃើញស្នាមភ្លើងឆេះរានហាលើផ្ទះចំនួនពីរកន្លែង។ លុះដល់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង ១០ និង៣០ នាទី ខ្លួនក៏ជិះម៉ូតូឌុបទៅប្រាប់ម្តាយខ្លួនឈ្មោះ[redacted]នៅឯរាជធានីភ្នំពេញមកប្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលព្រែកលួងតែម្តង។

Scanned by CamScanner

-អំណានចម្លើយសាក្សីឈ្មោះ [redacted]ានឆ្លើយថា៖ កន្លងមកឈ្មោ [redacted]ភេទប្រុស នៅភូមិឃុំជាមួយខ្លួន ឧស្សាហ៍ប្រើហិង្សាក្នុងគ្រួសារជាញឹកញាប់ ដោយវាយដំជេរប្រមាថប្រពន្ធរបស់ខ្លួនឈ្មោ [redacted]និងកូនៗ ព្រមទាំងវាយបំផ្លាញទ្រព្យសម្បត្តិនៅក្នុងផ្ទះ ចាន ឆ្នាំង ពាងទឹក បណ្តាលអោយបែកបាក់ខូចខាត។ លុះក្រោយមកដោយទ្រាំរស់នៅជាមួយប្តីតទៅទៀតលែងបាន ទើបឈ្មោះ [redacted]ដាក់ពាក្យបណ្តឹងនៅសាលាឃុំព្រែកល្វង លែងលះប្តីឈ្មោះ [redacted]នេះ។ លុះដល់ពេលលែងលះគ្នា ហើយឈ្មោះ [redacted]ក៏ទៅរស់នៅឯស្រុកកំណើតនៅស្រុកអង្គស្នួល ខេត្តកណ្តាល ចំណែកឈ្មោះ [redacted]ទៅធ្វើជាកម្មករសំណង់នៅរាជធានីភ្នំពេញ ដោយចាក់សោរផ្ទះទុកចោលគ្មានមនុស្សរស់នៅទេ។ រហូតដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង ២២ និង១៥ នាទី ពេលខ្លួនកំពុងតែដេកនៅលើផ្ទះខ្លួន ស្រាប់តែឮសំឡេងស្រែករបស់ឈ្មោ [redacted]ភេទប្រុស នៅភូមិឃុំជាមួយគ្នា ស្រែកហៅខ្លួនពីមុខផ្ទះថា [redacted] ចុះមកជីមក [redacted]វាដុតផ្ទះវាហើយ ពេលឮដូច្នេះខ្លួនក៏ក្រោកពីដំណេក បើកទ្វារផ្ទះចុះទៅដី បន្ទាប់មកឈ្មោះ [redacted] បាននាំខ្លួនរត់សំដៅទៅផ្ទះឈ្មោះ [redacted]ហើយឃើញភ្លើងឆេះសន្ធោសន្ធៅនៅរានហាលលើផ្ទះ ពេលទៅដល់ខ្លួន និងឈ្មោះ [redacted]ដងទឹកជួយពន្លត់អណ្តាតភ្លើងរលត់ទៅ ហើយពេលកើតហេតុពុំឃើញឈ្មោះ [redacted]នៅកន្លែងនេះទេ ពុំដឹងគេចទៅខាងណាទេ លុះភ្លើងរលត់អស់ ខ្លួន និងឈ្មោះ [redacted]ក៏បែកផ្លូវត្រឡប់ទៅផ្ទះរៀងៗខ្លួន ឯផ្ទះនោះខូចខាតអាចប្រហែល ០,៧០ ម៉ែត្រ។ ដល់ម៉ោង ២២ និង ៣០ នាទី យប់ថ្ងៃដដែល ដោយសង្ស័យខ្លាចក្រែងខ្លួន និងឈ្មោះ [redacted]ពន្លត់ភ្លើងមិនអស់ ខ្លាចឆេះរាលដាលដល់ផ្ទះអ្នកជិតខាង ខ្លួនក៏ដើរពីផ្ទះទៅមើលផ្ទះរបស់ឈ្មោ [redacted]ម្តងទៀត ដោយប្រុងប្រយ័ត្ន បាច់បំភ្លឺមើល ពេលទៅដល់ខ្លួនឃើញឈ្មោ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] កំពុងឈរជជែកគ្នានៅមុខផ្ទះនោះ បានបន្តិចក្រោយមកក៏ឃើញឈ្មោ [redacted]ជិះម៉ូតូពីទិសខាងត្បូងមកឈប់មុខផ្ទះរបស់ខ្លួន ឃើញដូច្នេះឈ្មោ [redacted]បានសួរទៅឈ្មោះ [redacted]ថាម៉េចក៏បងឯងដុតផ្ទះអញ្ចឹងទុកគ្រាន់ឱ្យកូនៗវានៅ កូនមានដល់២នាក់ ពេលឮដូច្នេះឈ្មោះ [redacted]ឆ្លើយតបថា អញដុតតែផ្ទះអញទេ ព្រោះគ្មានមនុស្សនៅ បន្ទាប់មកឈ្មោះ [redacted]បានជិះម៉ូតូបម្រុងគេចចេញពីទីនោះ តែត្រូវសមត្ថកិច្ចនគរបាលប៉ុស្តិ៍ព្រែកល្វងឃាត់ខ្លួនបាន បញ្ជូនទៅកាន់អធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្តាល។

-អំណានចម្លើយសាក្សីឈ្មោះ [redacted]បានឆ្លើយថា៖ កន្លងមកឈ្មោះ [redacted]ភេទប្រុស នៅភូមិជាមួយខ្លួន បានវាយបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្នុងផ្ទះ និងប្រពន្ធខ្លួនឈ្មោះ [redacted]ជាច្រើនដងមកហើយ។ រហូតដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង ២០ និង៣០ នាទី ពេលខ្លួនកំពុងអង្គុយហូបទឹកតែនៅផ្ទះរបស់ឈ្មោ [redacted]ជាប់ព្រំដីចំហៀងខាងត្បូងផ្ទះរបស់ឈ្មោ [redacted]លុះដល់វេលាម៉ោង ២១ និង០០នាទី ស្រាប់តែលឺសំលេងឈ្មោ [redacted] ស្រែកថា យប់នេះអញដុតផ្ទះនេះចោលហើយ ព្រោះគ្មានមនុស្សនៅ កន្ទួយម៉ែវា កូនមីចោលកញ្ចុយ។ ភ្លាមនោះខ្លួនក៏ដើរចេញមកមើលផ្ទះរបស់ឈ្មោះ [redacted]ឃើញភ្លើងឆេះរានហាលលើផ្ទះ ខ្លួនក៏រត់ទៅហៅឈ្មោះ [redacted]ជាមេភូមិក្តីចាស់ ឱ្យមកជួយពន្លត់ភ្លើង។ ពេលមកដល់ ខ្លួន និងឈ្មោះ [redacted]នាំគ្នាដងទឹកជះពន្លត់ភ្លើង

Scanned by CamScanner

ហើយពេលពន្លត់រួច ខ្លួនឃើញស្នាមឆេះលើរានហាលផ្ទះរបស់ឈ្មោះ [redacted] នូវពីរកន្លែង។ បន្ទាប់មកខ្លួនដើរមកដេកនៅផ្ទះរបស់ខ្លួន។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាៈ ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទ, សាក្សីឈ្មោះ [redacted] សាក្សីឈ្មោះ [redacted] សាក្សីឈ្មោះ [redacted] អាចបញ្ជាក់បានថា កាលពីថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១២ ជនជាប់ចោទឈ្មោះ [redacted] ពិតជាមានចេតនាដុតផ្ទះធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយអគ្គីភ័យ ដែលច្បាប់បញ្ញត្តិថាជាបទៈ អំពើធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការប្រើវិធីគ្រោះថ្នាក់ដល់បុគ្គល បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១៣ នៃក្រមព្រហ្មទណ្ឌ។ ហេតុដូច្នេះតំណាងអយ្យការសុំតម្កល់បទចោទដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ០៦០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ ទុកជាបានការដដែរ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយដើម្បីបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យសំណុំរឿងចប់គ្រប់

## សាលាដំបូងខេត្តកណ្តាល

## យល់ឃើញថា

១.ជនត្រូវចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា កាលពីទី២៧ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង ២០ និង០០ នាទី ខ្លួនបានឃើញផ្ទះរបស់ខ្លួនត្រូវបានចាក់សោរជិតពុំឃើញប្រពន្ធកូនខ្លួនឡើយ ខ្លួនក៏ឡើងយកខ្នើយមកដេកលេងនៅលើរានហាលតែម្នាក់ឯង ហើយដល់ម៉ោង២១ ខ្លួនបានយកដែកកេះ ពីហោប៉ៅយកទៅដុតខ្នើយដាក់លើរនាបផ្ទះធ្វើអំពីឬស្សីប្រាកដមែន។ ខ្លួនដឹងថាដុតខ្នើយដាក់លើរនាបផ្ទះ នឹងអាចបណ្តាលឱ្យឆេះផ្ទះ។

២.ដើមបណ្តឹងឈ្មោះ [redacted] បានឆ្លើយថាៈ កាលពីថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ២០១២ ខ្លួនបានទៅបានធ្វើការនៅកោះពេជ្រ ពេលខ្លួនកំពុងធ្វើការនោះស្រាប់តែកូនស្រីរបស់ខ្លួនឈ្មោះ [redacted] បានមកប្រាប់ខ្លួនថា ម៉ែអើយ ពុកដុតផ្ទះយើង ពេលឮដូចនេះខ្លួន ក៏ជិះម៉ូតូ ជាមួយកូនទៅមើលផ្ទះ ក៏បានឃើញរនាបឬស្សីផ្ទះរបស់ខ្លួនឆេះខូចខាតចំនួនពីរកន្លែង ដែលមានភាពស៊ីសង្វាក់គ្នាជាមួយចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយថា ពេលខ្លួនកំពុងនៅផ្ទះរបស់ យាយឈ្មោះ [redacted] ស្រាប់តែឈ្មោះ [redacted] មកប្រាប់ខ្លួនថាឪពុកចុងខ្លួនឈ្មោះ [redacted] បានដុតផ្ទះចោលហើយពេលឮដូចនេះខ្លួនទៅមើល ឃើញស្នាមឆេះរានហាលលើផ្ទះពីរកន្លែង ។

៣.សាក្សីឈ្មោះ [redacted] បានឆ្លើយថា នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង ២២ និង១៥ នាទី ពេលខ្លួនកំពុងដេកស្រាប់តែឮឈ្មោះ [redacted] ស្រែកហៅខ្លួនឲ្យចុះពីលើផ្ទះមក [redacted] ក

Scanned by CamScanner

ផ្ទះភ ហើយ បន្ទាប់មកឈ្មោះ [redacted]ានាំខ្លួនរត់សំដៅទៅផ្ទះរបស់ឈ្មោ [redacted] ហើយបាន ឃើញភ្លើងឆេះសន្ធោសន្ធៅនៅលើកនហាលលើផ្ទះ។

៤.សាក្សីឈ្មោះ [redacted] បានឆ្លើយថា នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង ២២ ពេលខ្លួនកំពុងអង្គុយហូបបាយនៅផ្ទះរបស់ឈ្មោះ [redacted] ស្រាប់តែឮសម្លេងរបស់ឈ្មោះ [redacted] ស្រែកថា "យប់នេះអញដុតផ្ទះនេះចោលហើយ ព្រោះគ្មានមនុស្សនៅ" ភ្លាមនោះខ្លួនក៏បានដើរ ចេញមកមើលឃើញភ្លើងឆេះកនហាលលើផ្ទះរបស់ឈ្មោ [redacted] តែម្តង។

៥.តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ [redacted] សាក្សីឈ្មោះ [redacted] សាក្សី ឈ្មោះ [redacted] សាក្សីឈ្មោះ [redacted] សៀវភៅរូបថតបង្ហាញទីតាំង និងស្នាមឆេះកនហាល និងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អាចបញ្ជាក់បានថា កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០១២ ជនជាប់ចោទ ពិតជាបានយកដែកកេះទៅដុតខ្នើយធ្វើឲ្យឆេះដល់រនាបផ្ទះរបស់ខ្លួន ប្រាកដ មែន ដែលអំពើនេះច្បាប់ចាត់ទុកថាជា អំពើធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយ សារការប្រើវិធីគ្រោះថ្នាក់ដល់បុគ្គល តាមបញ្ញត្តិមាត្រា ៤១៣ នៃក្រមព្រហ្មទណ្ឌ ។

៦.អំពើរបស់ជនត្រូវចោទឈ្មោះ [redacted] បានធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ រៀបរៀបរយសង្គម ប៉ះពាល់ដល់ទ្រព្យសម្បត្តិបុគ្គលឯកជន ហើយជនជាប់ចោទ ជានីតិជន មាន ស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវចំពោះអំពើ របស់ខ្លួន។

៧.មានភស្តុតាង និងធាតុផ្សំបទល្មើសគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ ពីបទៈ អំពើធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ ទោសដោយសារការប្រើវិធីគ្រោះថ្នាក់ដល់បុគ្គល ប្រព្រឹត្តនៅភូមិក្តីចាស់ ឃុំព្រែកលួង ស្រុកខ្សាច់ កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១២ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែង ឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១៣ នៃក្រមព្រហ្មទណ្ឌ។

៨.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មិនធ្វើការទាមទារសំណងរដ្ឋប្បវេណី ហេតុដូច្នេះ តុលាការមិនធ្វើការពិចារណាពីសំណងរដ្ឋប្បវេណីទេ។

៩.វត្ថុតាងដូចមានក្នុងកំណត់ហេតុទទួលវត្ថុតាងចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១២ មានដែក កេសហ្គាសពណ៌ក្រហមចំនួនមួយ គឺជាសម្ភារៈសម្រាប់ប្រើប្រាស់ប្រព្រឹត្តបទល្មើស គប្បីតុលាការ សម្រេចរឹបអូស។

**<u>ហេតុដូច្នេះសម្រេចសេចក្តី</u>**

១.ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ៤៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ ពីបទៈ អំពើធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស ដោយសារការប្រើវិធីគ្រោះថ្នាក់ដល់ បុគ្គល ប្រព្រឹត្តនៅភូមិក្តីចាស់ ឃុំព្រែកលួង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៧ ខែ

Scanned by CamScanner

វិច្ឆិកា ឆ្នាំ២០១២ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨១៣ នៃក្រមព្រហ្មទណ្ឌ ។

២.រឹបអូសវត្ថុតាងមាន ដែកកេសហ្គាសពណ៌ក្រហមចំនួនមួយ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនាថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៣ និងប្រកាសសាលក្រមជាសាធារណៈ នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជម្រះ**

[redacted]

21 មីនា 2013

[redacted]

[redacted]

26.3.2013

[redacted]